# បណ្តាំកសិករ

លំនាំបទៈ ពិសាខដើមឆ្នាំ

ហៃ... អឺងអើយ ... ហៃ... អឺងអើយ ...

ខ្ញុំសូមច្រៀងផ្តាំអោយញាតិ ចងចាំគ្រប់ៗអាត្មាអើយ កុំជឿពាក្យគេដើរឃោសនា
ធ្វើស្រែចំការផ្លាស់ប្តូរ ពូជថ្មី អើយ ជាល្បិចបំភាន់ដល់ញាតិប្រុសស្រី
ព្រោះអីស្រូវថ្មីទុកពូជមិនបានអើយ ដល់ពេលត្រូវការលោកអ្នកត្រូវទិញ
ព្រោះអីពូមីង អស់ពូជស្រូវចាស់ អើយ តំលៃគេឡើងយ៉ាងឆាប់រហ័ស
វាជាឱកាសដល់នាយទុនហើយហៃ អឺងអើយ វាជាឱកាស ដល់នាយទុនហើយហៃ អឺងអើយ ។

គេកេងចំណេញឥតឈប់ឈរឡើយ ទុក្ខគ្មានល្ហែល្ហើយដល់ញាតិគ្រប់ប្រាណ អើយ
ពូជថ្មីជីចាស់ផ្លាស់វិធីធ្វើ ញាតិអើយជួយមើលកាលពីដើមអើយ
យើងធ្វើពូជចាស់មិនខ្វះហូបឡើយ ឱពូមីងអើយជួយពិចារណា ហៃ អឺងអើយ
ឱពូមីងអើយជួយពិចារណា អើយ ។

ពេលប្រើពូជថ្មី ត្រូវការប្រើជី បាញ់ថ្នាំគីមី សំលាប់សត្វល្អិត អើយ
ធ្វើអោយដីខ្សោះអស់ជីជាតិ សុខភាពញោមញាតិក៏ត្រូវខូចដែរហៃ អឺងអើយ
សុខភាពញោមញាតិក៏ត្រូវខូចដែរអើយ ។

ហៃ...អឺងអើយ...ឯតំលៃជីឡើងកាន់តែខ្ទេរអើយ ធ្វើអោយអ្នកស្រែរស់មិនបានទេ អើយ
ដីខ្វះជីជាតិអើយ ពីមុនធ្វើស្រែប្រើជីធម្មជាតិ ឥឡូវភ្លាត់ស្នៀត ជឿតាមពាក្យគេអើយ
ត្រូវចំណាយច្រើនគ្មានលិទ្ធភាពទេ ត្រូវខ្ចីអើយលុយគេជារៀងរាល់ឆ្នាំ។
ហៃ អឺងអើយ គ្មានលុយទៅសងយកស្រែបញ្ចាំអើយ តើនេះជាកម្មឬមួយជាកល
សូមជួយប្រាប់ផងអើយ នេះហើយឯកជនភាវូបនិយកម្ម
ញាតិអើយចូរចាំថាវាមិនល្អអើយ ពេលវាមកដល់ធ្វើអោយវឹកវរ
ប្រជារាស្ត្រក្រករកអ្វីហូបគ្មាននេះហើយជាកលអើយ ប្រទេសអើយអ្នកមានដើម្បីឈ្នាន ពានប្រទេសក្រីក្រ ។

និពន្ធដោយៈ កម្មកររោងចក្រកាត់ដេរកម្ពុជា
ច្រៀងដោយៈ កម្មកររោងចក្រកាត់ដេរកម្ពុជា
© ២០០៥, កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ, ព្រះរាជាណាចក្រកម្ពុជា